**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
សំណុំរឿងព្រហ្មទណ្ឌលេខ: ១១៥
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩
សាលក្រមព្រហ្មទណ្ឌ
**លេខ: ៥០ (គ)**
ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តតាកែវ**

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តតាកែវ នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង៨ព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ឋាន:អនុប្រធានសាលាដំបូង ជាប្រធានក្រុមប្រឹក្សា
-លោក [redacted] ឋាន:ចៅក្រម ជាចៅក្រមប្រឹក្សា
-លោក [redacted] ឋាន:ចៅក្រម ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១១៥ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរអ្នកលេងភ្លេង ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] កូម៉ា (រស់) ម្តាយឈ្មោះ [redacted] ស្រី (រស់) នៅលីវ ជានីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី៩ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។ **(ឃុំខ្លួនថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩)**

-ជាប់ចោទពីបទ: រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិត្រពាំងស្នោ ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉េត ភេទស្រី អាយុ៥៩ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីលំនៅបច្ចុប្បន្នភូមិព្រៃធាតុ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ៥៥៥ ដសព១៨ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តតាកែវ ។

-បានឃើញដីកាដំណោះស្រាយលេខ: ៥០៨៥ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តតាកែវ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ០១៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ របស់ប្រធានសាលាដំបូងខេត្តតាកែវ ។

**អង្គហេតុមានដូចតទៅ**

-កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង១១និង១០នាទី ស្ថិតនៅភូមិត្រពាំងស្នោ ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា បានធ្វើសកម្មភាពរំលោភសេពសន្ថវៈ



Scanned with CamScanner

លើជនរងគ្រោះឈ្មោះ [redacted] វល័ក្ខ ហេតុបានសម្រេចនៅចំណុចលើផ្ទះរបស់ជនជាប់ចោទ។ ក្រោយកើតហេតុម្ដាយរបស់ជនរងគ្រោះឈ្មោះ [redacted] រ៉េត បានដាក់ពាក្យបណ្ដឹងទៅសមត្ថកិច្ច រួចសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រដ្ឋា និងកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តតាកែវ ចាត់ការតាមនីតិវិធីច្បាប់ ។

## ពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា បានឆ្លើយដោះសារថា: កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង៨ព្រឹក ខ្លួនបានហៅទូរស័ព្ទទៅឈ្មោះ [redacted] វល័ក្ខ ដែលត្រូវជាសង្សារចាស់របស់ខ្លួន ដើម្បីបបួលនាងទៅចូលរួមខួបកំណើតបងជីដូនមួយរបស់ខ្លួន។ មួយសន្ទុះក្រោយមកខ្លួនក៏បានជិះម៉ូតូទៅយកឈ្មោះ [redacted] វល័ក្ខ ដល់ផ្ទះ ហើយខ្លួនបានជួបឪពុករបស់ឈ្មោះ [redacted] វល័ក្ខ និងបានសុំអនុញ្ញាតពីឪពុកឈ្មោះ [redacted] វល័ក្ខ ដើម្បីយកឈ្មោះ [redacted] វល័ក្ខ ទៅចូលរួមខួបកំណើតជាមួយខ្លួន។ ខ្លួនបានឌុបឈ្មោះ [redacted] វល័ក្ខ ទៅផ្ទះរបស់ខ្លួន បន្ទាប់មកខ្លួនបានដឹកដៃនាងចូលក្នុងផ្ទះរបស់ខ្លួន និងបានឱបថើប ព្រមទាំងបានដោះខោអាវរបស់នាង ហើយបានរួមភេទជាមួយនាងតែម្ដង។ នៅពេលដែលខ្លួនរួមភេទជាមួយឈ្មោះ [redacted] វល័ក្ខ ខ្លួនបាននិយាយថាខ្លួនស្រលាញ់នាងដូចរាល់ដង ដោយខ្លួនពុំបានគំរាមកំហែងនាងអ្វីសោះឡើយ។ នៅពេលរួមភេទរួច ខ្លួនក៏បានចូលងូតទឹក ចំណែកឈ្មោះ [redacted] វល័ក្ខ ក៏បានរៀបចំខ្លួនដើរចេញទៅបាត់ទៅ។ ខ្លួនធ្លាប់រួមភេទជាមួយឈ្មោះ [redacted] វល័ក្ខ បានចំនួន២ដង ដោយលើកទី១នៅឆ្នាំ២០១៨ និងលើកទី២នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ហើយក្រោយមកក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉េត (អវត្តមាន) ក្រឡាបញ្ជីអានកំណត់ហេតុស្ដីពីការស្ដាប់ចម្លើយចំពោះមុខចៅក្រមស៊ើបសួរ (ឯកសារលេខ ២៦) ។

-ជនរងគ្រោះឈ្មោះ [redacted] វល័ក្ខ (អវត្តមាន) ក្រឡាបញ្ជីអានកំណត់ហេតុស្ដីពីការស្ដាប់ចម្លើយចំពោះមុខចៅក្រមស៊ើបសួរ (ឯកសារលេខ ២៥) ។

-ក្រឡាបញ្ជីអាន: ឯកសារនានាក្នុងសំណុំរឿង ។

## សិទ្ធិនិយាយស្ដីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា: ក្រោយពីបានពិនិត្យលើអង្គហេតុ ឯកសារនានានៅក្នុងសំណុំរឿង នៅពេលសវនាការនេះជនជាប់ចោទបានឆ្លើយសារភាពនៅការប្រព្រឹត្តរបស់ខ្លួន និងមានភស្ដុតាងគ្រប់គ្រាន់ បញ្ជាក់ឱ្យឃើញថា: ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា បានប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈប្រាកដមែន។ ដូច្នេះតំណាងអយ្យការនៅតែតំកល់ដីកាសន្និដ្ឋានស្ថាពរលេខ: ៥៥៥ ដសព១៨ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ ទុកជាបានការដដែល និងសុំឱ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-មេធាវីការពារសិទ្ធិជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលឃើញថាកូនក្ដីខ្លួនពុំបានប្រព្រឹត្តបទរំលោភសេពសន្ថវៈទេ អំពើរបស់កូនក្ដីខ្លួនគឺកើតឡើងដោយសារការស្រលាញ់គ្នា និងមានការរួមភេទដោយស្ម័គ្រចិត្ត និងពុំមានការបង្ខិតបង្ខំឡើយ។ អាស្រ័យហេតុនេះ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្ដីខ្លួនរួចខ្លួនពីបទចោទបទ រំលោភសេពសន្ថវៈ ។

## ផ្អែកតាមកិច្ចពិភាក្សាដេញដោល

-ក្រោយពីបានស្ដាប់ចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា

-ក្រោយពីបានស្ដាប់ការអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ការអានចម្លើយជនរងគ្រោះ

-ក្រោយពីបានពិនិត្យឯកសារនានាកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌



Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ
-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ ។

## សំអាងហេតុ

## តុលាការយល់ឃើញថា:

១-កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ពុំមានករណីរំលោភសេពសន្ថវៈដែលកើតឡើងនៅភូមិត្រពាំងស្មោ ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ បង្កឡើងដោយជនជាប់ចោទឈ្មោះ[redacted] វដ្ឋា នោះទេ ។

២-ជនជាប់ចោទឈ្មោះ[redacted] វដ្ឋា បានឆ្លើយដោះសារថា កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង៨ព្រឹក ខ្លួនបានហៅទូរស័ព្ទទៅឈ្មោះ [redacted] វល័ក្ខ ដែលត្រូវជាសង្សារចាស់របស់ខ្លួន ដើម្បីបបួលនាងទៅចូលរួមខួបកំណើតបងជីដូនមួយរបស់ខ្លួន។ មួយសន្ទុះក្រោយមកខ្លួនក៏បានជិះម៉ូតូទៅយកឈ្មោះ [redacted] វល័ក្ខ ដល់ផ្ទះ ហើយខ្លួនបានជួបឪពុករបស់ឈ្មោះ [redacted] វល័ក្ខ និងបានសុំអនុញ្ញាតពីឪពុកឈ្មោះ [redacted] វល័ក្ខ ដើម្បីយកឈ្មោះ [redacted] វល័ក្ខ ទៅចូលរួមខួបកំណើតជាមួយខ្លួន។ ខ្លួនបានឌុបឈ្មោះ [redacted] វល័ក្ខ ទៅផ្ទះរបស់ខ្លួន បន្ទាប់មកខ្លួនបានដឹកដៃនាងចូលក្នុងផ្ទះរបស់ខ្លួន និងបានឱបថើប ព្រមទាំងបានដោះខោអាវរបស់នាង ហើយបានរួមភេទជាមួយនាងតែម្តង។ នៅពេលដែលខ្លួនរួមភេទជាមួយឈ្មោះ [redacted] វល័ក្ខ ខ្លួនបាននិយាយថាខ្លួនស្រលាញ់នាងដូចរាល់ដង ដោយខ្លួនពុំបានគំរាមកំហែងនាងអ្វីសោះឡើយ។ នៅពេលរួមភេទរួច ខ្លួនក៏បានចូលងូតទឹក ចំណែកឈ្មោះ [redacted] វល័ក្ខ ក៏បានរៀបចំខ្លួនដើរចេញទៅបាត់ទៅ។ ខ្លួនធ្លាប់រួមភេទជាមួយឈ្មោះ [redacted] វល័ក្ខ បានចំនួន២ដង ដោយលើកទី១នៅឆ្នាំ២០១៨ និងលើកទី២នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ហើយក្រោយមកក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ចម្លើយដោះសារនេះមានហេតុផលគ្រប់គ្រាន់អាចឱ្យតុលាការជឿបាន ព្រោះចម្លើយនេះមានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] វល័ក្ខ បានបញ្ជាក់ថា នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] វដ្ឋា បានមកយកខ្លួនដើម្បីទៅចូលរួមខួបកំណើតប្អូនស្រីគាត់។ ពេលឈ្មោះ [redacted] វដ្ឋា ឌុបខ្លួនទៅដល់ផ្ទះគាត់ ឈ្មោះ[redacted] វដ្ឋា ក៏បានចាប់បីខ្លួនឡើងលើផ្ទះ រួចក៏ដាក់ខ្លួនលើកំរាលពូកតាមសម្រួល និងទៅបិទទ្វារ ហើយឈ្មោះ [redacted] វដ្ឋា បានប្រាប់ខ្លួនថា គាត់នៅតែស្រលាញ់ខ្លួន គាត់បានស្រាតខោរបស់ខ្លួន ហើយចង់ដោះអាវរបស់ខ្លួនទៀត តែខ្លួនពុំយល់ព្រម។ បន្ទាប់មកក៏បានរួមភេទជាមួយគ្នាបានប្រហែល២នាទីក៏បានសម្រេច ខ្លួនបានស្លៀកខោវិញ រួចខ្លួនទៅដងទឹកក្នុងពាង១ផ្តិលទៅលាងក្នុងបន្ទប់ទឹក ហើយខ្លួនក៏ត្រឡប់ទៅផ្ទះវិញ។ កន្លងមកខ្លួនធ្លាប់រួមភេទជាមួយឈ្មោះ [redacted] វដ្ឋា ចំនួន២លើកមកហើយ។ ក្នុងរឿងនេះខ្លួនមិនចង់ឱ្យឈ្មោះ[redacted] វដ្ឋា ជាប់ពន្ធនាគារទេ។

៣-ការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] រ៉េត ត្រង់ចំណុចថា ក្រោយពេលខ្លួនបានជួបកូនស្រីខ្លួនឈ្មោះ [redacted] វល័ក្ខ កូនស្រីខ្លួនបានរៀបរាប់ប្រាប់ពីដំណើររឿងឈ្មោះ [redacted] វដ្ឋា ចាប់រំលោភនាង។ ក្រោយពេលដឹងរឿងហេតុ ខ្លួនក៏បានទៅដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចតែម្តង។ ចំណុចនេះមិនមានលក្ខណៈត្រឹមត្រូវ បើផ្អែកតាមចម្លើយជនរងគ្រោះឈ្មោះ [redacted] វល័ក្ខ បានបញ្ជាក់ថា នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] វដ្ឋា បានមកយកខ្លួនដើម្បីទៅចូលរួមខួបកំណើតប្អូនស្រីគាត់។ ពេលឈ្មោះ[redacted] វដ្ឋា ឌុបខ្លួនទៅដល់ផ្ទះគាត់ ឈ្មោះ ញឹម វដ្ឋា ក៏បានចាប់បីខ្លួនឡើងលើផ្ទះ រួចក៏ដាក់ខ្លួនលើកំរាលពូកតាមសម្រួល និងទៅបិទទ្វារ ហើយឈ្មោះ [redacted] វដ្ឋា បានប្រាប់ខ្លួនថា គាត់នៅតែស្រលាញ់ខ្លួន គាត់បានស្រាតខោរបស់ខ្លួន ហើយចង់ដោះអាវរបស់ខ្លួនទៀត តែខ្លួនពុំយល់ព្រម។ បន្ទាប់មកក៏បានរួមភេទជាមួយគ្នាបានប្រហែល២នាទីក៏បានសម្រេច ខ្លួនបានស្លៀកខោវិញ រួចខ្លួនទៅដងទឹកក្នុងពាង១ផ្តិលទៅលាងក្នុងបន្ទប់ទឹក ហើយ



Scanned with CamScanner

ខ្លួនក៏ត្រឡប់ទៅផ្ទះវិញ។ កន្លងមកខ្លួនធ្លាប់រួមភេទជាមួយឈ្មោះ [redacted] រដ្ឋា ចំនួន២លើកមកហើយ។ សកម្មភាពនេះបង្ហាញឱ្យឃើញថាឈ្មោះ [redacted] រដ្ឋា និងឈ្មោះ [redacted] វល័ក្ខ បានព្រមព្រៀងរួមភេទដោយស្ម័គ្រចិត្តគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ។

៤-តាមរយៈអង្គហេតុ ភស្តុតាងនានា និងអំពើរបស់ឈ្មោះ [redacted] រដ្ឋា មិនមានធាតុផ្សំគ្រប់គ្រាន់ជាបទៈ រំលោភសេពសន្ថវៈ ទេ គឺជាការរួមភេទដោយស្ម័គ្រចិត្តរបស់អ្នកទាំង២ ពុំមានការបង្ខិតបង្ខំ និងគំរាមកំហែងទេ ម្យ៉ាងទៀតឈ្មោះ [redacted] រដ្ឋា និងឈ្មោះ [redacted] វល័ក្ខ គឺអ្នកទាំង២ធ្លាប់ជាសង្សារនឹងគ្នា និងធ្លាប់បានរួមភេទជាមួយគ្នាបានចំនួន២ដងផងដែរ។ អំពើនេះ ពុំមែនជាបទល្មើសព្រហ្មទណ្ឌទេ ។

៥-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ដែលបានប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ ញឹម រដ្ឋា ពីបទៈ រំលោភសេពសន្ថវៈ ឃើញថាពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ទេ ។

៦-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ បានស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ បទៈ រំលោភសេពសន្ថវៈ ដោយហេតុថា អំពើរបស់កូនក្តីខ្លួនគឺកើតឡើងដោយសារការស្រលាញ់គ្នា និងមានការរួមភេទដោយស្ម័គ្រចិត្ត និងពុំមានការបង្ខិតបង្ខំឡើយ ចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយជនរងគ្រោះឈ្មោះ [redacted] វល័ក្ខ ផងដែរ។ ការសន្និដ្ឋានសុំនេះ ឃើញថា មានហេតុផលសមរម្យអាចឱ្យតុលាការពិចារណាបាន ។

៧-ក្រោយពីបានពិនិត្យ និងពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថាៈ គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] រដ្ឋា ពីបទៈ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិត្រពាំងស្នោ ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះ គប្បីតុលាការសម្រេចឱ្យរួចខ្លួនពីបទចោទតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥០ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**<u>ហេតុដូច្នេះសម្រេច</u>**

១-ឱ្យឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ រួចខ្លួនពីបទចោទ បទៈ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិត្រពាំងស្នោ ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។ តាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥០ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រដ្ឋា និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉េត ។ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

---

| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| ថ្ងៃព្រហស្បតិ៍ ២រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ពស២៥៦៣ | ថ្ងៃព្រហស្បតិ៍ ២រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ពស២៥៦៣ |
| តាកែវ, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ | តាកែវ, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ |
| **ប្រធានក្រុមប្រឹក្សា** | **ក្រឡាបញ្ជីសវនាការ** |
| [redacted] | [redacted] |

Scanned with CamScanner